**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ០៥/១៩ ប.ស.ស/អល

# សេចក្តីជូនដំណឹង
# ស្តីពី
# ការអញ្ជើញចូលរួមដេញថ្លៃ

បេឡាជាតិរបបសន្តិសុខសង្គមសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា បេឡាជាតិរបបសន្តិសុខសង្គម នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ការផ្គត់ផ្គង់ប្រព័ន្ធកាម៉េរ៉ាសុវត្ថិភាព ។

បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មបេឡាជាតិរបបសន្តិសុខសង្គម អាស័យដ្ឋាន អាគារលេខ៣ ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ចាប់ពីថ្ងៃត្រឹមថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ នេះតទៅ រៀងរាល់ម៉ោងធ្វើការ (ព្រឹក៨:០០-១២:០០, រសៀល ១:០០-៥:០០) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១០:០០នាទី ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ នៅវេលាម៉ោង១០:០០នាទី។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃអង្គារ ៥កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**អ៊ុក_សមវិទ្យា**

**សូមទាក់ទង**
ទូរស័ព្ទលេខ ៖ ០១២ ៨៤៤ ៥០០

ចម្លងជូន ៖
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ